ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០៦៧.....សហវ.ខអ

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០១១

គោរពជូន

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

**កម្មវត្ថុ:** ករណីសំណើសុំថវិកាចំនួន ៣.៩៦៥.៩៨៦,១០ ដុល្លារអាមេរិក សម្រាប់ការងារជួសជុលទំនប់អាងត្រពាំងថ្ម។

**យោង:** លិខិតលេខ ១៤៦២ ធទឧ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមឯកភាពជាគោលការណ៍ផ្តល់នូវថវិកាចំនួន ៣.៩៦៥.000 ដុល្លារអាមេរិក (បីលានប្រាំរយហុកសិបប្រាំពាន់ដុល្លារអាមេរិក)ជូនក្រសួងធនធានទឹក និងឧតុនិយម សម្រាប់ការងារជួសជុលទំនប់អាងទឹកត្រពាំងថ្ម ស្ថិតក្នុងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ (តាមសំណើនៃគំនូសប្លង់) និងការងាររៀបចំសហគមន៍ដើម្បីថែទាំទំនប់អាងនេះ ដោយប្រើប្រាស់ថវិកាក្រោមហិរញ្ញប្បទានសហប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 2480-CAM(SF)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន តាមការគួរ ។

សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី
តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-សាលាខេត្តបន្ទាយមានជ័យ
-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបន្ទាយមានជ័យ
-ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798
mef_adm@yahoo.com